CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី 7 ខែមិថុនា ឆ្នាំ 2021
ទំនាក់ទំនង ៖ មជ្ឈមណ្ឌលព័ត៌មានរួម នៃសាលាក្រុងឡុងប៊ិច, 562.570.NEWS, jic@longbeach.gov

សម្រាប់ការផ្សព្វផ្សាយភ្លាមៗ

# សាលាក្រុង សម្ពោធបើក និងដាក់ឱ្យ ប៉មសេវាសង្គ្រោះជីវិត ញ៉ូវប្រាយ (New Pride Lifeguard Tower) បម្រើសេវា

## *សហគមន៍ ត្រូវបានអញ្ជើញឱ្យចូលរួម ក្នុងពិធីសម្ពោធដំណើរការប៉មនេះ*

ឡុងប៊ិច, CA - នៅថ្ងៃព្រហស្បតិ៍ ទី 10 ខែមិថុនា សាលាក្រុងឡុងប៊ិចនឹងអបអរសាទរ ការតម្លើង និងការដាក់ឱ្យដំណើរការ ប៉មសេវាសង្គ្រោះជីវិត ញ៉ូវប្រាយ (New Pride Lifeguard Tower) ស្ថិតនៅផ្លូវ សរ៍ឡាញ (Shoreline Way) និងកន្លែង ទី12 (12th Place) ។ សហគមន៍ ត្រូវបានអញ្ជើញឱ្យចូលរួម ក្នុងពិធីសម្ពោធដំណើរការប៉មនេះ ដែលគ្រោងចាប់ផ្តើម នៅម៉ោង 5 ល្ងាច ។

ចៅហ្វាយក្រុង រ៉ូប៊ើត ហ្គាសៀ (Mayor Robert Garcia) បានមានប្រសាសន៍ថា «ខ្ញុំមានមោទកភាពណាស់ ដែលឃើញប៉មសេវាសង្គ្រោះជីវិត របស់យើង ត្រឡប់មកជានិមិត្តរូប នៃបរិយាប័ន្ន និងសេចក្តីស្រឡាញ់វិញ ។» «ខ្ញុំក៏មានក្តីរំភើបផងដែរ សម្រាប់ដំណើរការសហគមន៍ ក្នុងការពង្រីកសណ្ឋានមុខងារ និងគ្រឿងជំនួយផាសុខភាព នៅជុំវិញប៉មនេះ ដើម្បីធ្វើឱ្យកន្លែងនេះ កាន់តែមានលក្ខណៈសកម្មថែមទៀត ។»

ដោយតម្លើងដោយ នាយកដ្ឋានអគ្គីភ័យ ឡុងប៊ិច, ប្រាង្គថ្មីនេះ ជំនួសឱ្យ នៅខែមីនា ឆ្នាំ 2021 ។ ក្រោយពីកើតឧបទ្ទវហេតុនេះរួចមក សាលាក្រុងបានទទួល ការគាំទ្រ យ៉ាងសន្ធឹកសន្ធាប់ ពីសមាជិកសហគមន៍ ធុរកិច្ច និងអង្គការនានា នៅទូទាំងតំបន់ ហើយការសាងសង់ប៉មថ្មី ត្រូវបានជំរុញ ឱ្យមានការដំណើការយ៉ាងឆាប់រហ័ស ។

កម្មវិធីសម្ពោធបើក និងដាក់ឱ្យដំណើរការនេះ នឹងរួមមាន ការបើកផ្ទាំងរបាំងប៉ម ដែលធ្វើឡើងដោយ ចៅហ្វាយក្រុង ហ្គាសៀ (Mayor Garcia) និង ស៊ីនឌី អាលែន សមាជិកាក្រុមប្រឹក្សាក្រុង (Councilwoman Cindy Allen) រួមទាំងការព្យួរ ពោងជ័រសង្គ្រោះ ព័រក្រហម (red Rescue Can) ដែលជា នីតិវិធីប្រតិបត្តិការជាបទដ្ឋាន បង្ហាញជូនសាធារណជនថា ប៉មសេវាសង្គ្រោះជីវិត កំពុងដំណើរការ ។

អាលែន សមាជិកា ក្រុមប្រឹក្សាក្រុង (Councilwoman Allen) បាននិយាយថា «ប៉មនេះ ស្ថិតដក់ជាប់ក្នុងចិត្តខ្ញុំ ជាពិសេស និងស្ថិតនៅក្នុងចិត្តយើងទាំងអស់គ្នា ។» «ការកសាងប៉មនេះឡើងវិញ ជាសញ្ញាប្រាប់កូនស្រីរបស់ខ្ញុំ និង បងប្អូនប្រុសស្រី សាច់ញាតិ និងគ្រួសារ របស់យើងថា យើងលើកកម្ពស់ បរិយាប័ន្ន អបអរសាទរពីភាពចម្រុះរបស់យើង ហើយធានាឱ្យមាន ភាពតំណាង និង លំហរសុវត្ថិភាព នៅក្នុងសហគមន៍ របស់យើង ។»

CITY OF LONG BEACH

# PRESS RELEASE

ហ្គន់ហ្សាឡូ មេឌីណា (Gonzalo Medina) ប្រធានផ្នែកសុវត្ថិភាពសមុទ្រ នៃនាយកដ្ឋានអគ្គីភ័យ ឡុងប៊ិច បានលើកឡើងថា «សេវាសង្គ្រោះជីវិត មានក្តីរំភើបណាស់ ដែលទទួលបាន ប៉មមោទកភាពនេះ ឱ្យមានវត្តមាន នៅលើឆ្នេរខ្សាច់ ដើម្បីបម្រើសេវា និងមានប្រតិបត្តិការ ឡើងវិញ ។» «ប៉មមោទកភាពនេះ តំណាងឱ្យ ការប្តេជ្ញាចិត្ត ឥតស្រាកស្រាន្ត របស់យើងខ្ញុំ ចំពោះនិយោជិត LGBTQ របស់យើង និងចំពោះសហគមន៍ប្រកបដោយភាពចម្រុះ នៅឡុងប៊ិច របស់យើង ។»

គណៈកម្មាធិការ ដែលដឹកនាំដោយ នឌី អាលែន សមាជិកាក្រុមប្រឹក្សាក្រុង (Councilwoman Cindy Allen) នឹងបណ្តុះគំនិត ដើម្បីលើកកម្ពស់ ប៉មមោទកភាពនេះ ឱ្យមានមធ្យោបាយបន្ថែមទៀត ក្នុងការបង្ហាញពីមោទកភាព LGBTQ+ ។ ប៉មថ្មីនេះ ដូចប៉មពីមុនមកដែរ នឹងត្រូវលាបពណ៌ ដោយកងសេវាសង្គ្រោះជីវិត របស់ក្រុង ។

ការស៊ើបអង្កេត ស្វែងរកបុព្វហេតុបង្ករអគ្គីភ័យ កាលពីខែមីនា នៅបន្តដំណើរការទៅមុខទៀត ។ មន្ត្រីស៊ើបអង្កេតអគ្គីភ័យ ឡុងប៊ិច បន្តធ្វើការពិនិត្យឡើងវិញ លើសេចក្តីថ្លែង ពីសាក្សីផ្សេងៗ និងស្រាវមើលតាមតម្រុយផ្សេងៗ ទៀត ។ ដំណើរការនេះ ត្រូវការពេលវេលាច្រើន ហើយតម្រូវឱ្យមានការប្រយ័ត្នប្រយ៉ែង ដើម្បីឱ្យប្រាកដថា បុព្វហេតុបង្ករអគ្គីភ័យ ត្រូវបានកំណត់ យ៉ាងហ្មត់ចត់ និងឱ្យប្រាកដថា មានគោរពច្បាប់ទាំងអស់ នៅក្នុងដំណើរការនេះ ។  ការស្រាវជ្រាវបានកំណត់រកឃើញថា គ្មានប្រភពចំហេះ ពាក់ព័ន្ធនឹង អគ្គិសនី ឬកម្តៅ មានវត្តមាន នៅក្នុងប៉មនេះទេ ។ ផ្អែកលើសេចក្តីថ្លែងសាក្សី និងការរកឃើញថាគ្មានប្រភពចំហេះ នៅក្នុងប៉មនោះ, អគ្គីភ័យនេះត្រូវបានចាត់ថ្នាក់ជា អគ្គីភ័យបង្ករដោយអ្នកលួចដុត (អគ្គីភ័យបង្ករដោយចេតនាមនុស្ស) ។ នាយកដ្ឋានអគ្គីភ័យ បន្តស្វែងរកជំនួយ ពីសាធារណជន ក្នុងការកំណត់រក វីដេអូ ខ្សែអាត់កាម៉េរ៉ាសុវត្ថិភាព ឬ គណនីសាក្សីឃើញផ្ទាល់ភ្នែក ពាក់ព័ន្ធនឹង ករណីអគ្គីភ័យនេះ បន្ថែមទៀត ។ អ្នកដែលមានព័ត៌មាន ត្រូវបានជំរុញ ឱ្យទូរសព្ទទៅ «បណ្ណាញទាន់ហេតុការណ៍ ផ្នែកស្រាវជ្រាវអគ្គីភ័យ» តាមរយៈលេខ (562) 570-2582 ។

# # #